*រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦*

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានរៀបចំ “**សិក្ខាសាលាស្តីការលើកកម្ពស់ការយល់ដឹងអំពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញ-វត្ថុសាធារណៈដល់យុវជនកម្ពុជា**” នៅសណ្ឋាគារភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមានការអញ្ជើញចូលរួមដោយឯកឧត្តម **ហ៊ុន ម៉ានី** ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក) ថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងយុវជន ស.ស.យ.ក ប្រមាណជាង ៨០០ នាក់ ។

គោលដៅចម្បងនៃសិក្ខាសាលាគឺផ្តោតសំខាន់ចំនួន ០៤គឺ (១)លើកកម្ពស់ និងបញ្ជ្រាបការយល់ដឹងអំពីសារៈសំខាន់ គុណតម្លៃ និងភាពចាំបាច់នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលដល់យុវជនកម្ពុជា, (២) ធ្វើការផ្សព្វផ្សាយពីការងារកែទម្រង់ពាក់ព័ន្ធចំនួន ២ ផ្សេងទៀតគឺ ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, (៣) ចែករំលែកនូវបទពិសោធ និងសមិទ្ធផលកន្លងមកនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង (៤) តួនាទីយុវជនចំពោះការងារកែទម្រង់ ។

ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី បានលើកឡើងនូវសាវតារសង្ខេបកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជូនដល់អង្គសិក្ខាសាលា រួមមាន÷

- ដំណាក់កាលទី ១ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានប្រកាសដាក់ឱ្យអនុវត្តនៅថ្ងៃទី ០៥ ខែ គោលដៅចម្បង គឺ “**ការបង្កើនភាពជឿទុកចិត្តនៃថវិកា**” ដោយផ្តល់អាទិភាពបន្ទាន់លើការងារពង្រឹងការប្រមូល និងការគ្រប់គ្រងចំណូល ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងការកែលម្អនីតិវិធីនៃការអនុវត្តថវិកា
- ដំណាក់កាលទី ២ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៨ ដែលគោលដៅចម្បងគឺ “**ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ**”
- ដំណាក់កាលទី៣ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តនៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ ដែលផ្តោតយកការចិត្តទុកដាក់ខ្ពស់លើ “**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**”។ ដំណាក់កាលបច្ចុប្បន្ននេះមានគោលចម្បងប្រែក្លាយប្រព័ន្ធថវិកាពី “***ប្រព័ន្ធថវិកាផ្តោតលើធាតុចូល និងមជ្ឈការ*” *ទៅជា* “*ប្រព័ន្ធថវិកាផ្តោតលើលទ្ធផល ឬធាតុចេញ និងវិមជ្ឈការ***”។
- ជាជំហានបន្ទាប់ ចាប់ពីឆ្នាំ២០២១ គឺបន្តពង្រឹងជាបណ្តើរឆ្ពោះទៅកាន់ “**ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម**” នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូលឱ្យសម្រេចបាននៅឆ្នាំ២០២៥ ដែលជា

គោលដៅចម្បងនៃដំណាក់កាលចុងក្រោយ គឺ ដំណាក់កាលទី ៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ជាលទ្ធផលដ៏សំខាន់នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគឺ ការប្រែក្លាយពីកង្វះសាច់ប្រាក់រ៉ាំរ៉ៃទៅជាអតិរេកសាច់ប្រាក់ ដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាលសម្រេចបានគោលដៅជាអាទិភាពរបស់ខ្លួន ជាពិសេសការដំឡើងបៀវត្សជូនមន្ត្រីរាជការ និងការបើកបៀវត្សទាន់ពេលវេលា ពោលគឺនៅសប្តាហ៍ទី ៤ ក្នុងខែនីមួយៗ ។

ជាលទ្ធផលសិក្ខាសាលា ១ ថ្ងៃនេះ សម្រេចបាននូវផ្លែផ្កាធំៗ ដូចខាងក្រោម ÷

(១) ផ្តល់ពុទ្ធិដល់យុវជនកម្ពុជាពីការងារកែទម្រង់របស់រាជរដ្ឋាភិបាល រួមមាន កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

(២) បានទទួលនូវការចូលរួមយ៉ាងសកម្ម និងកុះករពីយុវជនកម្ពុជា តាមរយៈការលើកជាសំណួរ និងចែករំលែកការយល់ដឹង និង

(៣) យុវជនយល់ដឹងពីតម្លៃ និងសារៈសំខាន់របស់ខ្លួនក្នុងការចូលរួមចំណែកនៅក្នុងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល។

ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រីក៏បានមានប្រសាសន៍ថា “**អ្វីដែលយើងបានធ្វើនៅថ្ងៃនេះនឹងក្លាយជាមរតកប្រវត្តិសាស្ត្រសម្រាប់មនុស្សជំនាន់ក្រោយ ហើយវានឹងជះឥទ្ធិពលដល់ថ្ងៃអនាគត**” ដែលសំដៅឱ្យមានការរួបរួមគ្នាកសាងប្រទេសដើម្បីបន្សល់មរតកដល់អ្នកជំនាន់ក្រោយ ។ ដោយមានការវាយតម្លៃខ្ពស់ចំពោះអត្ថប្រយោជន៍លើកម្មវិធីសិក្ខាសាលានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងរៀបចំឱ្យមានសិក្ខាសាលាបែបនេះបន្តទៀតដើម្បីជំរុញ និងបង្កើនការផ្សព្វផ្សាយការយល់ដឹង និងការចូលរួមពីសំណាក់ សិស្ស និស្សិត យុវជន និងសាធារណជនពីគ្រប់មជ្ឈដ្ឋាន ។